NSW HEALTH

ខែឧសភា ឆ្នាំ២០០៧ /May 2007 **KHMER**

**SHP: (CDB) 07/098 (Khm)**

# ថ្នាំព្យាបាលជម្ងឺរបេង

## ព័ត៌មានសំរាប់អ្នកជម្ងឺ

## TUBERCULOSIS MEDICATIONS
## Information for patients

អ្នករៀបនឹងចាប់ផ្តើមនូវដំណាក់ការព្យាបាលដែលចេញឲ្យដោយវេជ្ជបណ្ឌិតដើម្បីព្យាបាលជម្ងឺរបេង (TB) របស់អ្នក។ ជម្ងឺ TB គឺជាជម្ងឺសាហាវមួយដែលនឹងធ្វើឲ្យខូចខាតដល់សុខភាពរបស់អ្នក ប្រសិនបើទុកចោលដោយមិនបានព្យាបាល។ គេអាចព្យាបាលជម្ងឺ TB ដាច់ទាំងស្រុង ដោយប្រើថ្នាំព្យាបាលត្រឹមត្រូវ។

### *ការត្រួតពិនិត្យ*

នេះគឺជាការសំខាន់ដែលអ្នកត្រូវប្រើថ្នាំព្យាបាលដែលវេជ្ជបណ្ឌិតបានចេញឲ្យប្រើ។ ការប្រើថ្នាំព្យាបាលមិនបានទៀងទាត់អាចបណ្តាលឲ្យមានការប្រឆាំងទប់ទល់នឹងថ្នាំ ហើយធ្វើឲ្យជម្ងឺរបស់អ្នកពិបាកនឹងព្យាបាល។

ដើម្បីចៀសវាងបញ្ហាទាំងនេះ គ្រប់ទាំងការព្យាបាលជម្ងឺ TB ត្រូវបានគេត្រួតពិនិត្យយ៉ាងពេញលេញ។ នេះបានន័យថាអ្នកត្រូវ ប្រើថ្នាំព្យាបាលនៅចំពោះមុខគិលានុប្បដ្ឋាក ឬអ្នកធ្វើការផ្នែកមើលថែដទៃទៀត។ គិលានុប្បដ្ឋាកនៅមន្ទីរព្យាបាលជម្ងឺ TB អាច ឆ្លើយនឹងសំនួរណាមួយដែលអ្នកមាន អំពីការព្យាបាលជម្ងឺ TB របស់អ្នក។ ពួកគេអាចនឹងពិនិត្យឃ្លាំមើលនូវផលវិបាករាយរង ណាមួយនៃការព្យាបាល ហើយប្រសិនបើមានការចាំបាច់ នឹងលៃលកឲ្យអ្នកទៅជួបវេជ្ជបណ្ឌិត។

នេះគឺជាការ**សំ ខាន់ ចាំ បាច់** ដែលអ្នកត្រូវបន្តការប្រើថ្នាំព្យាបាល រហូតទាល់តែមន្ទីរព្យាបាលជម្ងឺ TB របស់អ្នក ប្រាប់ឲ្យអ្នកឈប់ប្រើ (ទោះបីជាអ្នកមានអារម្មណ៍គ្រាន់បើក្តី) ដើម្បីការពារកុំឲ្យជម្ងឺ TB ត្រឡប់មកវិញបាន។

### *ហេតុអ្វីបានជាខ្ញុំត្រូវការប្រើថ្នាំព្យាបាលទាំងនេះ?*

- ដើម្បីឲ្យបានជាដាច់ស្រឡះពីជម្ងឺ TB
- ដើម្បីការពារកុំឲ្យកើតមាននៃការទ្រាំទ្រពីការជាដាច់ស្រឡះនៃជម្ងឺ TB; ហើយនិង
- ដើម្បីការពារការរាលដាលនៃជម្ងឺ TB

### *តើគេប្រើថ្នាំព្យាបាលណាខ្លះដើម្បីព្យាបាលជម្ងឺ TB*

ថ្នាំព្យាបាលដែលប្រើសំរាប់ព្យាបាលជម្ងឺ TB តាមធម្មតាគឺជាថ្នាំផ្សះហៅថា Isoniazid, Rifampicin, Pyrazinamide ហើយនិង Ethambutol។ ថ្នាំទាំងនេះត្រូវវេជ្ជបណ្ឌិតចេញប្រើជារៀងរាល់ថ្ងៃ ឬ៣ដង ក្នុង១អាទិត្យ។

អ្នកត្រូវប្រើថ្នាំទាំងនេះដូចបានណែនាំដោយវេជ្ជបណ្ឌិតរបស់អ្នក ឲ្យបានយ៉ាងហោចណាស់ចំនួន៦ខែ។ នៅក្នុងករណីខ្លះដែល កម្រនឹងកើតមាន ការព្យាបាលអាចត្រូវការបន្តរហូតដល់ទៅ២ឆ្នាំ។

សូមឲ្យបានច្បាស់ប្រាកដថាអ្នកត្រូវជំរាបប្រាប់គិលានុប្បដ្ឋាកឲ្យបានដឹង ប្រសិនបើដោយមូលហេតុណាមួយដែលអ្នកមិនអាច មកកាន់មន្ទីរព្យាបាលជម្ងឺ TB បើមិនដូច្នោះទេសូមរៀបចំឲ្យគិលានុប្បដ្ឋាយកមកជួបអ្នកនៅផ្ទះ (ឧទាហរណ៍ ប្រសិនបើអ្នកមានការណាត់ជួបមួយផ្សេងទៀត) នៅចំថ្ងៃដែលអ្នកត្រូវប្រើថ្នាំព្យាបាល នុះយើងនឹងរៀបចំលៃលកផ្សេងទៀតសំរាប់អ្នក។

*ហេតុអ្វីបានជាមានថ្នាំព្យាបាលច្រើនមុខខុសៗគ្នា ប្រើក្នុងពេលជាមួយគ្នា?*

ថ្នាំព្យាបាលជម្ងឺ TB គឺជាថ្នាំផ្សំ។ ថ្នាំទាំងនេះធ្វើការរបៀបខុសៗគ្នាដើម្បីសម្លាប់បាក់តេរីនៃជម្ងឺ TB។ បាក់តេរីនៃជម្ងឺ TB ស្លាប់ដោយយឺតៗ ហើយតម្រូវឲ្យមានការប្រើថ្នាំព្យាបាលរួមផ្សំគ្នា ឲ្យបានយ៉ាងហោចណាស់៦ខែ ដើម្បីសម្លាប់បាក់តេរីទាំងនេះ។

ប្រសិនបើប្រើថ្នាំព្យាបាលទីទៃពីគ្នា បាក់តេរីនៃជម្ងឺ TB អាចក្លាយទៅជាមានកម្លាំងទប់ទល់នឹងថ្នាំបានយ៉ាងឆាប់រហ័ស។ នៅក្នុងប្រទេសអូស្ត្រាលី មានមនុស្សមួយក្រុមតូចដែលកើតជម្ងឺ TB ដែលអាចទប់ទល់ទៅនឹងថ្នាំប្រើសំរាប់ព្យាបាលជម្ងឺ TB។ ប្រសិនបើមានហេតុការណ៍នេះកើតឡើង ថ្នាំផ្សំបន្ថែមទៀតអាចត្រូវប្រើ ហើយការព្យាបាលអាចត្រូវការប្រើពេលយូរជាងនេះ។

*ការប្រុងប្រយ័ត្ននៅពេលកំពុងព្យាបាលជម្ងឺ TB*

សុរា ហើយនិងថ្នាំផារ៉ាស៊ីតាម៉ុល អាចជ្រៀតជ្រែកដល់ថ្នាំព្យាបាល។ ការពិសាសុរា ឬលេបថ្នាំផារ៉ាស៊ីតាម៉ុល ក្នុងពេលដែលអ្នក កំពុងប្រើថ្នាំព្យាបាលជម្ងឺ TB អាចបណ្តាលឲ្យមានប្រតិកម្ម ឬកើតមានផលវិបាករាយរង ដែលអាចធ្វើឲ្យខូចខាតដល់សុខភាព របស់អ្នក។ អ្នកត្រូវបានទូន្មានឲ្យជៀសវាងការពិសាសុរាក្នុងរយៈពេលព្យាបាលរបស់អ្នក។

សូមកត់សម្គាល់ថា ការមានរដូវមិនទៀងទាត់ ក៏អាចកើតមានឡើងផងដែរក្នុងអម្លុងពេលព្យាបាលជម្ងឺ។ នេះត្រូវបានណែនាំថា ស្ត្រីទាំងឡាយត្រូវចៀសវាងការមានផ្ទៃពោះ ក្នុងអម្លុងពេលព្យាបាលជម្ងឺ TB។ ឥទ្ធិពលនៃថ្នាំលេបការពារកុំឲ្យមានផ្ទៃពោះត្រូវ បានថយចុះដោយសារថ្នាំ Rifampicin ធ្វើឲ្យវិធីការពារកុំឲ្យមានផ្ទៃពោះនេះពុំអាចទុកចិត្តបាន។ នេះត្រូវបានណែនាំថាស្ត្រីដែល កំពុងទទួលការព្យាបាលជម្ងឺ TB ត្រូវប្រើវិធីការពារកុំឲ្យមានផ្ទៃពោះផ្សេងទៀត។ ចំពោះវិធីការពារកុំឲ្យមានផ្ទៃពោះតាមរបៀប ផ្សេងទៀត ត្រូវពិភាក្សាជាមួយវេជ្ជបណ្ឌិតរបស់អ្នក។

ប្រសិនបើអ្នក**មានផ្ទៃពោះ ឬកំពុងបំបៅកូននឹងទឹកដោះ** សូមប្រាប់វេជ្ជបណ្ឌិតព្យាបាលជម្ងឺ TB របស់អ្នកឲ្យបានភ្លាមៗ។ ថ្នាំព្យាបាលដែលអ្នកកំពុងប្រើ អាចតម្រូវឲ្យប្តូរចេញ។

ការធ្វើតេស្តឈាមយ៉ាងទៀងទាត់អាចតម្រូវឲ្យមាន ដើម្បីពិនិត្យមើលផលវិបាករាយរងទាំងឡាយដែលអាចកើតមាន។ វេជ្ជបណ្ឌិតរបស់អ្នកនឹងរៀបចំការធ្វើតេស្តទាំងនេះជូនអ្នក។

*ឥទ្ធិពលទៅវិញទៅមកកើតមានពីថ្នាំព្យាបាល*

នេះគឺជាការសំខាន់ដែលត្រូវប្រាប់វេជ្ជបណ្ឌិតព្យាបាលជម្ងឺ TB ឲ្យបានដឹង ប្រសិនបើអ្នកប្រើថ្នាំព្យាបាលដទៃទៀត ឬប្រើថ្នាំព្យា បាលធម្មជាតិផ្សំដោយរុក្ខជាតិ ដើម្បីឲ្យយើងអាចវាយតម្លៃលើលទ្ធភាពនៃការប៉ះពាល់ទាំងឡាយ ដែលថ្នាំព្យាបាលដទៃទៀត មានលើការព្យាបាលជម្ងឺ TB របស់អ្នក។

ថ្នាំបន្សាបជាតិអាស៊ីដដែលមានបំណែកជាតិអាលុយមីនីញ៉ូម (ឧទាហរណ៍ Gaviscon) មិនត្រូវប្រើក្នុងរយៈពេល២ម៉ោងនៃការប្រើថ្នាំព្យាបាលជម្ងឺ TB ទេ ការព្យាបាលឲ្យរួចពីជាតិគ្រឿងញៀន ក៏អាចមានឥទ្ធិពលទៅវិញទៅមកលើថ្នាំព្យាបាលជម្ងឺ TB ដែរ។ ថ្នាំការព្យាបាល diabetes (រោគទឹកនោមផ្អែម), Parkinson’s disease (ជម្ងឺសសៃប្រសាទធ្វើឲ្យញ័រដៃជើង), HIV, epilepsy (ជម្ងឺឆ្កួតជ្រូក), ឬ cardiac (ជម្ងឺបេះដូង) អាចមានប្រតិកម្មជាមួយថ្នាំព្យាបាលជម្ងឺ TB។ ប្រសិនបើអ្នក កំពុងព្យាបាលជម្ងឺណាមួយទាំងនេះ នេះគឺជាការសំខាន់ដែលអ្នកត្រូវប្រាប់វេជ្ជបណ្ឌិតព្យាបាលជម្ងឺ TB របស់អ្នកឲ្យបានដឹង។

## *របៀបប្រើថ្នាំព្យាបាល*

ការប្រើថ្នាំព្យាបាលនឹងមានប្រសិទ្ធិភាពល្អប្រសើរ ប្រសិនបើអ្នកលេបជាមួយគ្នា១ម៉ោង ឬ២ម៉ោងក្រោយការទទួលទានអាហារ ហើយយកល្អត្រូវលេបជាមួយទឹក។ ជាការសមរម្យបំផុត ត្រូវលេបថ្នាំឲ្យបានទៀងទាត់ពេលវេលាជាទៀងរាល់ថ្ងៃ។

ចំពោះអ្នកជម្ងឺដែលមានដំណើរចង់ក្អួត គេអាចលេបថ្នាំជាមួយចំណីបន្តិចបន្តួច (ឧទាហរណ៍ បន្ទះនំប័ុងអាំង)។ ប្រសិនបើអ្នកកើតមានដំណើរចង់ក្អួត នេះគឺជាការសំខាន់ដែលអ្នកត្រូវប្រាប់គិលានុប្បដ្ឋាក ឬវេជ្ជបណ្ឌិតឲ្យបានដឹង។

ប្រសិនបើអ្នកមានបញ្ហាក្នុងការលេបថ្នាំរបស់អ្នក សូមពិភាក្សាអំពីរឿងនេះជាមួយគិលានុប្បដ្ឋាក ឬវេជ្ជបណ្ឌិតជម្ងឺ TB។

## *ប្រតិកម្មរាយរងនៃថ្នាំព្យាបាលជម្ងឺ TB*

ដូចគ្នានឹងថ្នាំព្យាបាលទាំងអស់ដែរដែលប្រើដើម្បីព្យាបាលជម្ងឺ TB ម្តងម្កាលអាចបណ្តាលឲ្យកើតមានប្រតិកម្មរាយរងខ្លះៗនៅក្នុងចំណោមមនុស្សខ្លះ។ ប្រសិនបើកើតមានហេតុទាំងនេះ សូមរាយការណ៍ទៅវេជ្ជបណ្ឌិត ឬបុគ្គលិកគិលានុប្បដ្ឋាកនៅមន្ទីរព្យាបាលជម្ងឺ TB ជាបន្ទាន់។

ប្រសិនបើអ្នកជួបប្រទះនូវរោគសញ្ញាមិនធម្មតាណាមួយ ឬមានអារម្មណ៍មិនស្រួលខ្លួនដោយរបៀបណាមួយ សូមពិភាក្សាអំពីបញ្ហានេះជាមួយគិលានុប្បដ្ឋាក ឬវេជ្ជបណ្ឌិតព្យាបាលជម្ងឺ TB របស់អ្នក។ ក្នុងករណីយដែលអ្នកត្រូវការការព្យាបាលជាបន្ទាន់ក្រៅម៉ោងធ្វើការ សូមទៅមន្ទីរព្យាបាលក្នុងគ្រាបន្ទាន់នៃមន្ទីរពេទ្យប្រចាំតំបន់របស់អ្នក **ដោយយកមកជាមួយផងដែរ នូវបញ្ជីរាយឈ្មោះថ្នាំព្យាបាលជម្ងឺ TB។**

ប្រតិកម្មរាយរងទាំងឡាយដែលអាចកើតមាន គឺរាប់បញ្ចូល ក៏ប៉ុន្តែមិនមានកំណាត់តែត្រឹមនេះទេ:

- ឡើងកន្ទួល ហើយរមាស់
- មានដំណើរចង់ក្អួត (មានអារម្មណ៍មិនស្រួលខ្លួន) បាត់ឃ្លានចំណីអាហារ
- ប្រែពណ៌លឿងនៅលើស្បែក និងភ្នែក
- ការនឿយហត់ហួសប្រមាណ
- ព្រិលភ្នែក មើលមិនឃើញពណ៌
- មានរដូវមិនទៀងទាត់
- ចុះរាក
- ឈឺសន្លាក់ដៃជើងខុសពីធម្មតា/រលាកសន្លាក់ឆ្អឹង
- គ្រុន ឈឺក្បាល និងឈឺសាច់ដុំ
- មានស្នាមជាំកាន់តែខ្លាំង

ទឹកភ្នែកប្រែពណ៌លឿងទុំ កែវដាក់ក្នុងភ្នែកឡើងទន់ កំហាក និងទឹកមូត្រច្រើនតែកើតមានឡើង ក្នុងពេលកំពុងទទួលថ្នាំព្យាបាលជម្ងឺ TB ហើយមិនបណ្តាលឲ្យមានការព្រួយបារម្ភអ្វីទេ។

**សូមកុំស្ទាក់ស្ទើរក្នុងការពិភាក្សាអំពីចំណុចសំខាន់ៗណាមួយនៃការព្យាបាលរបស់អ្នក ជាមួយវេជ្ជបណ្ឌិត ឬគិលានុប្បដ្ឋាកព្យាបាលជម្ងឺ TB នៅមន្ទីរព្យាបាលរបស់អ្នក។**

**សេចក្តីយោង:**


1. Therapeutic Guidelines, Antibiotic, Version 12, 2003
2. Department of Health, Controlling Tuberculosis in NSW 2005